**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**អគ្គលេខាធិការដ្ឋាន**

លេខ ៤៤/២០១៧ អ.កបធ ត.ស.៣

# បទបញ្ជាសម្រាប់ការប្រឡងជ្រើសរើសបេក្ខជន ចូលបម្រើការងារនៅអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

ដើម្បីរក្សាសណ្តាប់ធ្នាប់ របៀបរៀបរយ វិន័យ និងតម្លាភាព ក្នុងការប្រឡង បេក្ខជនទាំងអស់ត្រូវគោរពបទបញ្ជាសម្រាប់ការប្រឡងដូចខាងក្រោម៖

**I-បទបញ្ជា**

បេក្ខជនទាំងអស់ត្រូវ៖

១-យកមកជាមួយនូវសលាប័ត្រឯកត្តជន ដើម្បីបង្ហាញអនុរក្ស។

២-មកដល់មណ្ឌលប្រឡងឱ្យបានមុនពេលដំណើរការប្រឡង។

៣-ប្រកាន់អាកប្បកិរិយាសមរម្យ ថ្លៃថ្នូរ។

៤-គោរពការណែនាំរបស់អនុរក្ស។

៥-បំពេញក្បាលសន្លឹកកិច្ចការប្រឡងឱ្យបានត្រឹមត្រូវ គ្រប់គ្រាន់ តាមការណែនាំរបស់អនុរក្ស។

៦-សរសេរលើសន្លឹកកិច្ចការសម្រាប់ធ្វើវិញ្ញាសាសរសេរដែលចែកជូនដោយអនុរក្ស។

៧-ប្រើប្រាស់សន្លឹកកិច្ចការទាំងមូល ដើម្បីតាក់តែងចម្លើយ។

៨-ប្រើក្រដាសព្រាងដែលមានត្រាអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ដែលរៀបចំដោយអនុរក្ស និងត្រូវចុះលេខតុ និងលេខបន្ទប់របស់បេក្ខជននៅចុងសន្លឹក។

៩-សុំការអនុញ្ញាតពីអនុរក្ស នៅពេលមានធុរៈចាំបាច់ ឬ ទៅបន្ទប់ទឹក។

១០-ប្រគល់សន្លឹកកិច្ចការជូនអនុរក្សវិញនៅពេលដល់ម៉ោងកំណត់ ទោះបីជាកិច្ចការនោះធ្វើរួចរាល់ ឬ មិនរួចរាល់ក្តី។

១១-រក្សាសណ្តាប់ធ្នាប់ របៀបរៀបរយ ក្នុងពេលប្រឡង និងគោរពឱ្យបានត្រឹមត្រូវតាមការណែនាំផ្សេងៗទៀតដែលត្រូវអនុវត្តក្នុងពេលប្រឡង។

បេក្ខជនទាំងអស់មិនត្រូវ៖

១-យកសំណៅឯកសារច្បាប់ សៀវភៅច្បាប់ ខ្មៅដៃ ឯកសារ កំណត់ត្រាផ្សេងៗ ឬ សម្ភារដទៃទៀតដូចជា អាវុធជាតិផ្ទុះ ទូរស័ព្ទ វិទ្យុទាក់ទងផ្សេងៗ កុំព្យូទ័រ ឬឧបករណ៍អេឡិចត្រូនិច ឬ